**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...០៦...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់វិទ្យាស្ថានសិក្សាដើម្បីជោគជ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជននិងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជននិងកីឡា
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

## សម្រេច

**មាត្រា១.-**

ត្រូវបានទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា "**វិទ្យាស្ថានសិក្សាដើម្បីជោគជ័យ**" សរសេរជាអក្សរកាត់ថា "**វសជ**" និងជាភាសាអង់គ្លេសថា Learning for Success Institute សរសេរជាអក្សរកាត់ថា " LSI "។

**មាត្រា២.-**

វិទ្យាស្ថានសិក្សាដើម្បីជោគជ័យមានទីតាំងស្ថិតនៅ ភូមិពោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ វិទ្យាស្ថាននេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៣.-**

វិទ្យាស្ថានសិក្សាដើម្បីជោគជ័យ ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ លើដេប៉ាតឺម៉ង់ចំនួន ២(ពីរ) ដូចខាងក្រោម ៖

**១.ដេប៉ាតឺម៉ង់គ្រប់គ្រងសហគ្រាស និងធនធានមនុស្ស**

**-កម្រិតបរិញ្ញាបត្រ៖** - មុខជំនាញការអភិវឌ្ឍធនធានមនុស្ស និង

- មុខជំនាញគ្រប់គ្រងសហគ្រាសខ្នាតតូចនិងមធ្យម

**២.ដេប៉ាតឺម៉ង់ភាសាអង់គ្លេស**

**-កម្រិតបរិញ្ញាបត្រ៖** មុខជំនាញភាសាអង់គ្លេសសម្រាប់ធុរកិច្ច

**-កម្រិតបរិញ្ញាបត្ររង៖** មុខជំនាញភាសាអង់គ្លេស

ទៅអនាគតវិទ្យាស្ថាននេះអាចបើកសាខា មហាវិទ្យាល័យថ្មី ដេប៉ាតឺម៉ង់ថ្មី មុខជំនាញថ្មី កម្រិតបណ្តុះបណ្តាលថ្មី សុំប្តូរឈ្មោះថ្មី ទីតាំងថ្មី ឬពង្រីកទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជននិងកីឡា។

**មាត្រា៤.-**

វិទ្យាស្ថានសិក្សាដើម្បីជោគជ័យ ត្រូវមានក្រុមប្រឹក្សាភិបាលមួយ ដើម្បីត្រួតពិនិត្យនិងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃវិទ្យាស្ថានសិក្សាដើម្បីជោគជ័យ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអប់រំ យុវជននិងកីឡា។

**មាត្រា៥.-**

នាយកវិទ្យាស្ថានសិក្សាដើម្បីជោគជ័យ មានភារកិច្ច ដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវិទ្យាស្ថានសិក្សាដើម្បីជោគជ័យ និងធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម
- ទទួលខុសត្រូវក្នុងការទទួលសិស្ស និស្សិតឱ្យចូលរៀន និងការបញ្ចប់ការសិក្សា ស្របតាមបទដ្ឋានកំណត់របស់ក្រសួងអប់រំ យុវជននិងកីឡា
- រៀបចំបង្កើតថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជននិងកីឡា ជាមុនសិន មុននឹងជ្រើសរើសនិស្សិតចូលរៀនឆ្នាំទីមួយ កម្រិតបរិញ្ញាបត្រ
- រៀបចំកម្មវិធីសិក្សាលម្អិតឱ្យស្របតាមលក្ខខណ្ឌនិងបទប្បញ្ញត្តិនៃក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា

- គោរពនិងអនុវត្តតាមបទដ្ឋាននិងគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំឧត្តមសិក្សា
- ធ្វើរបាយការណ៍ប្រចាំឆ្នាំអំពីការងារបណ្តុះបណ្តាល ជូនក្រសួងអប់រំ យុវជន និងកីឡា នៅក្រោយដំណាច់ឆមាសទី២។

**មាត្រា៦..**

និស្សិតនៃវិទ្យាស្ថានសិក្សាដើម្បីជោគជ័យ ដែលរៀនចប់កម្មវិធីសិក្សា ហើយនិងទទួលជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រ តាមកម្រិតនិងឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះ ត្រូវផ្តល់ឱ្យដោយវិទ្យាស្ថានសិក្សាដើម្បីជោគជ័យ ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីវិទ្យាស្ថានសិក្សាដើម្បីជោគជ័យ បំពេញនិងអនុវត្តតាមគោលការណ៍និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជននិងកីឡា។

**មាត្រា៧..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងនាយកវិទ្យាស្ថានសិក្សាដើម្បីជោគជ័យ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ២ កើត ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ